**SBS**

# Media Release

5 October 2021




## SBS ស្វែងរកមតិយោបល់ ពីសហគមន៍ ដើម្បីជួយ រៀបចំអនាគតរបស់  វិទ្យុ SBS និង សេវាកម្មភាសា

ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់SBS ក្នុងការ បន្តវិវឌ្ឍន៍ ដើម្បីបំពេញតម្រូវការប្រទេសអូស្ត្រាលីនាពេលបច្ចុប្បន្ន SBSបានចាប់ផ្តើម ដំណើរ ការពិនិត្យឡើងវិញជាទៀងទាត់មកលើសេវាកម្មភាសា របស់ ខ្លួនដែលបានផ្តល់ជូនតាមរយៈវិទ្យុ SBS ដោយបើកការពិគ្រោះយោបល់ជាសាធារណៈនៅថ្ងៃនេះ ដើម្បីសុំមតិយោបល់កែលម្អលើសេចក្តីព្រាងនៃលក្ខណៈវិនិច្ឆ័យ ក្នុងការជ្រើសរើស។

ការពិនិត្យឡើងវិញលើសេវាកម្មភាសាSBS គឺជាដំណើរការមួយដែលធ្វើឡើងរៀងរាល់៥ឆ្នាំម្តងស្របតាមជំរឿនប្រជាជនដើម្បីធានាថា សេវាកម្មវិទ្យុSBSឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងការកើនឡើងនៃសង្គមដ៏សម្បូរបែបរបស់អូស្ត្រាលី។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសនឹងត្រូវប្រើរួមគ្នាជាមួយទិន្នន័យជំរឿនឆ្នាំ២០២១ ដើម្បីកំណត់ភាសាដែលត្រូវបម្រើសេវាកម្ម និងជួយប្រាប់ពីវិធីដែលសេវាកម្មទាំងនោះត្រូវបានផ្តល់ជូនក្នុងរយៈពេល ៥ឆ្នាំខាងមុខ។

ការពិនិត្យឡើងវិញលើសេវាកម្មភាសានេះដាក់បញ្ចូលការផ្តល់ជូននូវមាតិកា សំឡេង និងភាសារបស់ SBS រួមមានវិទ្យុ SBS On Demand ការផ្សាយតាមផតខាស្ត៍ និងវេទិកាឌីជីថលផ្សេងទៀត។ ការពិគ្រោះយោបល់ជាសាធារណៈរយៈពេល ៦សប្តាហ៍ ដែលចាប់ផ្តើមឡើងនៅថ្ងៃនេះ និងបញ្ចប់នៅថ្ងៃទី ១២ ខែវិច្ឆិកាឆ្នាំ ២០២១ គឺជាឱកាសដ៏សំខាន់សម្រាប់សហគមន៍ក្នុងការចូលរួមចំណែកដល់អនាគតនៃសេវាកម្មវិទ្យុ SBS និងការផ្តល់ជូននូវមាតិកាសំឡេងនិងភាសារបស់បណ្តាញនេះ ឲ្យកាន់ តែទូលំទូលាយ ដោយមតិយោបល់ទាំងអស់ត្រូវបានពិចារណាក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសចុងក្រោយ ដែលនឹងត្រូវបានយក ទៅប្រើប្រាស់។

នាយកមាតិកាសំឡេងនិងភាសារបស់SBS លោក ដេវីដ ហ័រ មានប្រសាសន៍ថា “SBSមានសមត្ថភាព ពិសេសក្នុងការ ទៅឲ្យដល់ និងទំនាក់ទំនងជាមួយសហគមន៍ចម្រុះរបស់អូស្ត្រាលីតាមរយៈសេវាកម្មពហុភាសារបស់ខ្លួន ឆ្លងកាត់ចំណុចទំនាក់ទំនងជាច្រើន។ អស់រយៈពេលជាង៤៥ឆ្នាំមកហើយ យើងបានបន្តសម្របខ្លួនតាមវិធីដែលយើងផ្តល់សេវាកម្មប្រកបដោយភាពច្នៃប្រឌិត និងមានអត្ថន័យដល់សហគមន៍ ហើយសព្វថ្ងៃនេះយើងធ្វើដូច្នេះតាមវិទ្យុ តាម អ៊ិនធឺណេត តាមផតខាស្ត៍ និងតាមកម្មវិធីអ៊ែពជាង ៦០ ភាសា។ ការពិនិត្យឡើងវិញនេះនឹងជួយរៀបចំ SBS នៅពេលយើងសម្លឹងឆ្ពោះទៅរកការឈានចូលវ័យ៥០ឆ្នាំ។

“តួនាទីដ៏សំខាន់នៃសេវាកម្មពហុភាសារបស់SBS ត្រូវបានបង្ហាញក្នុងអំឡុងពេលមានរោគ រាតត្បាតកូវីដ-១៩ ដោយផ្តល់ជូននូវព័ត៌មានថ្មីៗ និងព័ត៌មានសុខភាពដល់សហគមន៍ជាភាសាដែលពួកគេពេញចិត្ត។
ការពិនិត្យឡើងវិញលើសេវាកម្មភាសានេះគឺជាឱកាសដ៏សំខាន់មួយដើម្បីធានាថាយើងបន្តឆ្លុះបញ្ចាំងពីតម្រូវការរបស់សហគមន៍នៅក្នុងប្រទេសអូស្ត្រាលីនាពេលបច្ចុប្បន្ននេះ។

“ការធ្វើបច្ចុប្បន្នភាពលើការផ្តល់ជូនសេវាកម្មភាសារបស់យើងជាប្រចាំអាចជួយឱ្យSBSផ្តល់ជូននូវសេវាកម្មកាន់តែល្អប្រសើរដល់សហគមន៍ធំៗ ដែលមានប្រវត្តិ វប្បធម៌ និងភាសាចម្រុះ ក៏ដូចជាផ្តល់សេវាកម្មដល់សហគមន៍ដែលកំពុងលេចធ្លោនិងមានតម្រូវការខ្ពស់។
ការផ្តល់សំឡេងដល់ទស្សនិកជនរបស់យើងនៅក្នុងដំណើរការនេះគឺជាកត្តាដ៏សំខាន់មួយហើយយើងលើកទឹកចិត្តសហគមន៍នៅទូទាំងប្រទេសអូស្ត្រាលីឱ្យចែករំលែកមតិយោបល់របស់ពួកគេ” ។

លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសនេះគឺត្រូវបញ្ចប់នៅត្រឹមខែឧសភាឆ្នាំ២០២២ ដោយសេវាកម្មភាសាSBSដែលត្រូវបានកែសម្រួលថ្មី នឹងត្រូវអនុវត្តមុនដំណាច់ឆ្នាំ ២០២២ ។

រយៈពេលពិគ្រោះយោបល់ជាសាធារណៈសម្រាប់លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសមានចាប់ពីថ្ងៃទី ៥ ខែតុលាដល់ថ្ងៃទី ១២ ខែវិច្ឆិកាឆ្នាំ ២០២១ ។
ដើម្បីចូលមើលសេចក្តីព្រាងនៃលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស និងបញ្ចេញមតិយោបល់របស់អ្នក សូមចូលទៅកាន់ sbs.com.au/consultation ។

សម្រាប់ ព័ត៌មាន បន្ថែម និង ការ ស្នើសុំសម្ភាសន៍ សូមទាក់ទង៖ Kate Warnock | kate.warnock@sbs.com.au | 0419 316 135